# ការថែរក្សាដំណាំធូរេនក្នុងពេលផ្តល់ផ្កា និងផ្លែ



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម
loan 2022-CAM[SF]
2007

# ការថែរក្សាដំណាំធូរេន ក្នុងពេលផ្តល់ផ្កា និងផ្លែ

ការថែទាំដំណាំធូរេនក្នុងដំណាក់កាលផ្តល់ផ្កា និងផ្លែ គឺជាប្រការសំខាន់ណាស់ ព្រោះអាចធ្វើឱ្យធូរេនរបស់បងប្អូនប្រជាកសិករ អាចចេញផ្កា និងកាន់ផ្លែបានច្រើន និងផ្តល់គុណភាពសាច់ល្អ ។

## ១. ការត្រៀមដើម



គឺជាការត្រៀមដើមធូរេនដែលមានលក្ខណៈល្អ និងមានសារធាតុបំរ៉ុងគ្រប់គ្រាន់ ។ កាលណាធូរេនមានស្លឹកបែកមែកសាខាពេញដើម គ្មានភ្លៀង ដីមិនសូវមានសំណើម អាកាសធាតុចាប់ផ្តើមចុះត្រជាក់ ធូរេនក៏ចាប់ផ្តើមចេញផ្កា ។

ដើម្បីថែរក្សា និងធ្វើឱ្យធូរេនកាន់ផ្លែបានច្រើន

បងប្អូនប្រជាកសិករចាំបាច់ត្រូវការអនុវត្តការងារមួយចំនួនដូចខាងក្រោមនេះ ៖

## ២. ការកាត់តែងមែក ៖

បន្ទាប់ពីប្រមូលផលរួចត្រូវប្រញាប់កាត់មែកងាប់ៗ ឬមែកមានជម្ងឺ និងខ្មែងមិនល្អដែលដុះនៅក្នុងមែកដែលនឹងផ្តល់ផ្លែផ្កានោះចេញ។ ត្រូវលាបថ្នាំគីមីនៅមុខស្នាមកាត់ដើម្បីការពារពពួកមេរោគហ្វាំងគីស ឬពពួកវីរុស្លធ្លើក។



បន្ទាប់ពីកាត់តែងមែក ត្រូវបំផ្លាញរុក្ខជាតិចង្រៃឱ្យអស់ រួចហើយជ្រៃដីដើម្បីដាក់ជី។ ជីដែលត្រូវដាក់មាន៖

- ជីអាចម៍សត្វកំរិតពី ១៥-៥០ គ.ក្រ/ដើម

- ជី ១៥.១៥.១៥ ឬ ជី ១៦.១៦.១៦ កំរិត ៣-៥ គីឡូក្រាមក្នុងធូរេន ១ ដើម ។

- បើសិនជាភ្លៀងធ្លាក់ច្រើន ត្រូវធ្វើប្រឡាយបង្ហូរទឹកចេញពីគល់ធូរេន ។

- បើសិនជាគ្មានភ្លៀងធ្លាក់ត្រូវធ្វើការស្រោចទឹក

- ត្រូវកំចាត់រុក្ខជាតិចង្រៃដោយកាប់ជំរះឱ្យបានស្អាតជុំវិញគល់ ។

- ត្រូវការពារកុំឱ្យមានជម្ងឺរលួយឬស រលួយគល់ងាប់ស្លឹក ដែលបណ្តាលមកពីពពួកសត្វល្អិតចំលងរោគដូចជាខ្ចូតមាន់ អង្រ្កង និងខ្ចូតភ្លើង ។

- នៅពេលមិនសូវមានភ្លៀងធ្លាក់ ត្រូវដាក់ជីគីមី ៨.២៤.២៤, ៩.២៤.២៤, ឬ ១៧.២៤.១២ ចំនួន ២-៣ គ.ក្រ/ដើម ដើម្បីជំរុញឱ្យធូរេនឆាប់ចេញផ្កា ។

- នៅរដូវភ្លៀងជោគជាំត្រូវបោសកំទេចស្មៅ និងស្លឹកធូរេនដែលជ្រុះចេញពីគល់ ដើម្បីឱ្យដីឆាប់ស្ងួត ហើយត្រូវផ្អាកការផ្តល់ទឹក ១០-១៤ ថ្ងៃ ។ នៅពេលឃើញស្លឹកធូរេន ចាប់ផ្តើមស្វិត ត្រូវផ្តល់ទឹកបន្តិចម្តងៗ ដើម្បីឱ្យដើមធូរេនចេញផ្កា ប៉ុន្តែកុំឱ្យខ្វះទឹកយូរពេករហូតដល់ស្លឹកលឿងហើយជ្រុះ ដែលបណ្តាលឱ្យភ្នែកចេញផ្កាមកមិនរួច ។ ហើយក៏មិនត្រូវផ្តល់ទឹកឱ្យច្រើនពេកដែរ ព្រោះកញ្ចុំផ្កាអាចក្លាយជាស្លឹកបាន ។ ការផ្តល់ទឹកដែលសមស្រប គឺត្រូវផ្តល់ដោយល្វៃយ៉ាងណាកុំអោយជោគជាំ

ពេក។ ទន្ទឹមនេះត្រូវសង្កេតមើលលក្ខណៈរបស់ស្លឹក និងផ្កា ពេលឃើញផ្កាមានលក្ខណៈស្រដៀងពងត្រី មានចំនួនច្រើន ត្រូវធ្វើការផ្ដល់ទឹកឱ្យបានច្រើនតាមប្រក្រតីឡើងវិញ ។

- ពេលចេញផ្កា ៧ ទៅ ១០ ថ្ងៃ រហូតទៅដល់ផ្ការីក និងពេលចេញត្រួយត្រូវបន្ថយការស្រោចទឹកត្រឹម ២ ភាគ ៣ នៃការផ្ដល់ទឹកតាមប្រក្រតី ។

## ៣. ការកាត់តែងផ្កា ៖

**គឺសំដៅធ្វើឱ្យធូរេនកាន់ផ្កាបានល្អ ៖**

- កាត់ផ្កាដែលនៅតាមមែកតូចៗ ឬចុងមែកចេញ
- គួរកាត់តែងផ្កាធូរេននៅក្នុងចន្លោះពេលផ្កាមានលក្ខណៈដូចជាត្របំពុតញ្ញង រហូតដល់ផ្កាមានលក្ខណៈដូចជាបន្តោងកងដៃ
- បើសិនមានផ្កាច្រើនក្នុងទងជាមួយគ្នា ត្រូវកាត់ឱ្យសល់ត្រឹមចំនួនដែលសមរម្យ ។
- បើសិនជាមានផ្កា ២ ផ្នែក ឬក្រុមផ្សេងគ្នាត្រូវកាត់ផ្កានៅផ្នែកណាមួយដែលមានចំនួនច្រើនឱ្យនៅត្រឹមចំនួនតិចតួច។ តែបើសិនជាផ្កាមានចំនួនតិចត្រូវរក្សាទុកតាមធម្មជាតិរបស់វា ។
- ទុកផ្កាក្រុមជាមួយគ្នាលើទងតែមួយ
- ទុកផ្កាក្រុមជាមួយគ្នាលើទងដែលនៅជិតគ្នា
- បើសិនជាទុកផ្កាក្រុមផ្សេងគ្នាលើទងជិតគ្នា ត្រូវគិតថាគួរទុកប្រភេទណាមួយច្រើនជាងគេ ។



## ៤. ការកាត់តែងផ្លែ

- ក្រោយពីផ្ការីក ៣-៤ សប្ដាហ៍ត្រូវកាត់ផ្លែណាមួយដែលមានសភាពវៀចឬផត ផ្លែមានទំហំតូច ឬផ្លែមានក្រុមផ្សេងគ្នា និងផ្លែដែលមានទំរង់មិនសមរម្យ ។ ដូចជាផ្លែដែលស្ថិតនៅចុងមែក ចំហៀងទង និងផ្លែជាប់គ្នាណែនណាន់តាន់តាប់កញ្ចុំធំៗ ។ ត្រូវបេះផ្លែណាដែលមិនល្អចេញដូចជា ផ្លែមានរាងសំប៉ែត និងផ្លែណាដែលមានបន្លាក្រហម ហើយទុកតែផ្លែណាដែលយើងត្រូវការពិតប្រាកដឱ្យនៅត្រឹមចំនួន ៥០ ភាគរយ ។

**រៀបរៀង និងបោះពុម្ពផ្សាយដោយ៖**

**ក្រុមការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម**